Date: 01/08/2022 Vol:1 Issue: 8 RF

ព្រឹត្តិបត្រព័ត៌មាន
NEWSLETTER

# កិច្ចសហប្រតិបត្តិការ រវាងសាកលវិទ្យាល័យនិងឧស្សាហកម្ម ជាឧបករណ៍គោលនយោបាយដើម្បី អភិវឌ្ឍប្រព័ន្ធរៀនសូត្រជាតិរបស់កម្ពុជា

(ដោយៈ បណ្ឌិត ថាច់ ប៊ុនរឿន ព្រឹទ្ធបុរសរងមហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍)

ទស្សនាទានទំនាក់ទំនងរវាងសាកលវិទ្យាល័យនិងឧស្សាហកម្មត្រូវបានជ្រើសរើសជាធម្មតាដោយប្រទេសអភិវឌ្ឍន៍ ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធច្នៃប្រឌិតជាតិ។ ទស្សនាទាននេះ បានក្លាយទៅជាមានសារៈសំខាន់កាន់តែខ្លាំងសម្រាប់ប្រទេសដែលកំពុងអភិវឌ្ឍ ដើម្បីអភិវឌ្ឍនូវប្រព័ន្ធរៀនសូត្រជាតិក្នុងការគាំទ្រវិស័យឯកជន ដើម្បីបង្កើតនូវគុណសម្បត្តិប្រកួតប្រជែងរបស់ពួកគេ។ ក្រុមហ៊ុនតម្រូវឱ្យមានការអភិវឌ្ឍនូវអង្គការចាត់តាំងនៅក្នុងក្រុមហ៊ុនដើម្បីជួយលើកទឹកចិត្តនូវភាពទំនាក់ទំនងគ្នារវាងប្រព័ន្ធទីផ្សារ ប្រព័ន្ធផលិតកម្ម ប្រព័ន្ធស្រាវជ្រាវនិងការអភិវឌ្ឍ(R&D) និងប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍនូវគំនិតច្នៃប្រឌិតបច្ចេកវិទ្យា និងការអនុវត្តក្រុមហ៊ុន(Lundvall, 2009)។

ភាពទំនាក់ទំនងអន្តរក្រុមហ៊ុនក៏មានសារៈសំខាន់ផងដែរចំពោះការលើកទឹកចិត្តនូវទំនាក់ទំនងរវាងមនុស្សក្នុងក្រុមហ៊ុនផ្សេងៗគ្នាដើម្បីរៀនសូត្រនូវចំណេះដឹងថ្មីៗនិងបច្ចេកវិទ្យា។ ទំនាក់ទំនងរវាងសាកលវិទ្យាល័យឬស្ថាប័នស្រាវជ្រាវនិងអភិវឌ្ឍន៍ជាមួយក្រុមហ៊ុនគឺមានសារៈសំខាន់ណាស់ ពីព្រោះក្រុមហ៊ុនអាចរៀនសូត្រនូវចំណេះដឹងនិងបច្ចេកវិទ្យាថ្មីពីសាកលវិទ្យាល័យបាន(Freeman, 2004)។ ទោះបីយ៉ាងណាក៏ដោយប្រទេសដែលកំពុងអភិវឌ្ឍគឺនៅមានកម្រិតទាបនៃការទាក់ទងរវាងសាកលវិទ្យាល័យនិងឧស្សាហកម្ម ដោយសារតែភាពមានកម្រិតនៃសមត្ថភាពគ្រប់គ្រងក្នុងចំណោមសាកលវិទ្យាល័យនិងក្រុមហ៊ុន។ ប្រទេសកម្ពុជាគឺត្រូវបានគេចាត់ថ្នាក់ថាទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងឧស្សាហកម្មគឺនៅខ្សោយ ពីព្រោះទាំងសាកលវិទ្យាល័យនិងឧស្សាហកម្មនៅមានសមត្ថភាពគ្រប់គ្រងក្នុងកម្រិតមូលដ្ឋានប៉ុណ្ណោះ។

ភាពជាដៃគូរវាងសាធារណៈ និងឯកជននៅក្នុងការទាក់ទងរវាងសាកលវិទ្យាល័យនិងឧស្សាហកម្ម គួរតែត្រូវបានអភិវឌ្ឍដើម្បីផលិតនូវបច្ចេកវិទ្យាថ្មីនិងគំនិតច្នៃប្រឌិត និងធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការអប់រំនិងការហ្វឹកហ្វឺន ដើម្បីផ្គត់ផ្គង់ធនធានមនុស្សឱ្យត្រូវនឹងតម្រូវការឧស្សាហកម្ម។ រដ្ឋាភិបាលមានតួនាទីដ៏សំខាន់ក្នុងការលើកកម្ពស់នូវទំនាក់ទំនងសាកលវិទ្យាល័យនិងឧស្សាហកម្ម ដោយការផ្តល់នូវប្រព័ន្ធលើកទឹកចិត្តក្នុងទម្រង់ផ្សេងៗគ្នា ដើម្បីតម្រង់ទិសកិច្ចសហប្រតិបត្តិការដោយផ្ទាល់នៅក្នុងវិស័យអាទិភាព។ សហគ្រាសបានណែនាំនូវតម្រូវការបច្ចេកទេសទៅអ្នកស្រាវជ្រាវក្នុងសាកលវិទ្យាល័យនិងប្រើប្រាស់ទំនាក់ទំនងរវាងសាកលវិទ្យាល័យនិងឧស្សាហកម្ម ដើម្បីអនុវត្តសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍រួមគ្នាក្នុងគោលបំណងស្វែងរកនូវដំណោះស្រាយបច្ចេកទេស។




ឧបករណ៍គោលនយោបាយដើម្បីអភិវឌ្ឍប្រព័ន្ធរៀនសូត្រជាតិរបស់កម្ពុជា

តម្រូវការបច្ចេកទេសរបស់ពួកគេគឺមានទំហំធំ ប្រសិនបើពួកគេព្យាយាមអភិវឌ្ឍនូវប្រព័ន្ធបច្ចេកវិទ្យា ដើម្បីផលិតនូវផលិតផលថ្មី ឬដំណើរការផលិតកម្មថ្មី។ម៉្យាងទៀតសាកលវិទ្យាល័យដើរតួនាទីជាអ្នកគ្រប់គ្រងទំនាក់ទំនងសាកលវិទ្យាល័យនិងឧស្សាហកម្មដើម្បីត្រួតពិនិត្យពីលំហូរហិរញ្ញវត្ថុនៃគម្រោងកិច្ចសហប្រតិបត្តិការ ដើម្បីផ្តល់នូវការលើកទឹកចិត្តដ៏សមរម្យនិងបរិយាកាសស្រាវជ្រាវនិងអភិវឌ្ឍន៍ច្បាស់លាស់សម្រាប់ឱ្យអ្នកស្រាវជ្រាវអនុវត្តសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍។ ជាចុងក្រោយអ្នកស្រាវជ្រាវបានដើរតួនាទីក្នុងការអនុវត្តសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ និងផ្តល់ការប្រឹក្សាយោបល់កែលម្អសម្រាប់អ្នកស្រាវជ្រាវដទៃទៀតក្នុងការអភិវឌ្ឍអាជីពដំបូងរបស់ពួកគេ(CDRI, 2018B)។

ប្រទេសកម្ពុជាបានជ្រើសរើសនូវទស្សនាទានទំនាក់ទំនងសាកលវិទ្យាល័យនិងឧស្សាហកម្ម ដើម្បីគាំទ្រវិស័យឯកជន។ ទោះបីយ៉ាងណាក៏ដោយទំនាក់ទំនងសាកលវិទ្យាល័យនិងឧស្សាហកម្មគឺនៅមានកម្រិតទាបនៅឡើយ។ ការទំនាក់ទំនងនេះនៅតែមិនអាចជំរុញលើកកម្ពស់គុណភាពអប់រំនិងមិនអាចជួយអភិវឌ្ឍផ្សព្វផ្សាយនិងប្រើប្រាស់នូវគំនិតច្នៃប្រឌិត។ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី៨២ នៅក្នុង១៤១ប្រទេសក្នុងកិច្ចសហប្រតិបត្តិការភាគីពាក់ព័ន្ធជាច្រើនក្នុងសន្ទស្សន៍នៃការប្រកួតប្រជែងសកលនៅក្នុងឆ្នាំ២០១៨ ស្ទើរតែស្មើនឹងប្រទេសវៀតណាមដែលជាប់ចំណាត់ថ្នាក់ទី៨០ ប៉ុន្តែនៅតែខ្សោយជាងប្រទេសថៃដែលជាប់ចំណាត់ថ្នាក់ទី៤០ (WEF, 2019)។ ដោយប្រើប្រាស់នូវប៉ាន់គំរូចំនួន៤៦ ដែលការចូលរួមពីស្ថាប័នដែលពាក់ព័ន្ធ Sam et al.(2017) បានរកឃើញថាទោះបីជាប្រភេទភាគីពាក់ព័ន្ធ ដូចជារដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ស្ថាប័នអប់រំឧត្តមសិក្សា(HEIs) និងឧស្សាហកម្មមានទំនាក់ទំនងគ្នាក្នុងកម្រិតជាក់លាក់មួយក្នុងការអភិវឌ្ឍវិស័យអប់រំ កម្រិតឧត្តមសិក្សា កិច្ចសហប្រតិបត្តិការរបស់ពួកគេនៅតែទន់ខ្សោយ។

ភស្តុតាងដ៏ជាក់លាក់នេះបានបង្ហាញថា រដ្ឋាភិបាលនិងម្ចាស់ជំនួយបានដើរតួនាទីដ៏សំខាន់ក្នុងការអនុម័តគោលនយោបាយ និងការធ្វើអន្តរាគមន៍ហិរញ្ញវត្ថុដើម្បីគាំទ្រវិស័យអប់រំកម្រិតឧត្តមសិក្សា ទោះបីជាយន្តការលើកទឹកចិត្តកិច្ចសហប្រតិបត្តិការនៅតែអវត្តមានក៏ដោយ។ ឧស្សាហកម្មនិងអង្គការក្រៅរដ្ឋាភិបាល(NGO) បានដើរតួនាទីមានដែនកំណត់ជានិយោជកផ្តល់ការងារអ្នកផ្តល់ការចុះកម្មសិក្សានិងអ្នកផ្តល់ការហ្វឹកហ្វឺនការងារដោយសារតែការខ្វះខាតនៃសមត្ថភាពនិងធនធាន ដើម្បីទំនាក់ទំនងជាមួយស្ថាប័នឧត្តមសិក្សា។

ស្ថាប័នឧត្តមសិក្សាខ្លួនឯងក៏ខ្វះសមត្ថភាពខាងមុខងារនិងធនធាន ដើម្បីអភិវឌ្ឍធនធានមនុស្សឱ្យត្រូវនឹងតម្រូវការរបស់ឧស្សាហកម្ម។ បន្ថែមពីលើហ្នឹងទៀត ពួកគេគឺមិនមានផែនការយុទ្ធសាស្ត្រដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយឧស្សាហកម្មនិងភាគីពាក់ព័ន្ធដទៃៗទៀត ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍ និងការផ្សព្វផ្សាយគំនិតច្នៃប្រឌិតនៅក្នុងសេដ្ឋកិច្ចដែលអាស្រ័យទៅលើចំណេះដឹង (knowledge-based economy)។ ដោយយោងទៅលើ Sam et al.(2016) កម្ពុជាប្រឈមមុខយ៉ាងខ្លាំងក្នុងការតម្រង់ទិសវិស័យអប់រំកម្រិតឧត្តម ដើម្បីឱ្យបត់បែនបានទៅតាមនិន្នាការតំបន់ ឬពិភពលោកដែលមានទំនោរអភិវឌ្ឍសាកលវិទ្យាល័យឱ្យក្លាយជាសាកលវិទ្យាល័យសហគ្រិនភាព។ ការទំនាក់ទំនងទន់ខ្សោយរវាងសាកលវិទ្យាល័យ និងឧស្សាហកម្មបានធ្វើឱ្យសាកលវិទ្យាល័យនៅក្នុងប្រទេសកម្ពុជាបាត់បង់ឱកាសទទួលបានប្រភពចំណូលផ្សេងៗរបស់ពួកគេនិងមិនអាចជំរុញលើកកម្ពស់គុណភាពនៃការអប់រំកម្រិតឧត្តម និងការអភិវឌ្ឍសេដ្ឋកិច្ច។ ខណៈពេលដែលសមាជិក ASEAN ដទៃទៀត ដូចជា Malaysia, Singapore និងThailand ព្យាយាមអភិវឌ្ឍសាកលវិទ្យាល័យរបស់ពួកគេឱ្យក្លាយទៅជាសាកលវិទ្យាល័យសហគ្រិនភាព កម្ពុជាបានជ្រើសរើសនូវម៉ូឌែលនៃសាកលវិទ្យាល័យបែបពាណិជ្ជកម្ម។

ទោះបីជាប្រទេសកម្ពុជាមានក្រុមហ៊ុនគំនិតច្នៃប្រឌិតនៅមានចំនួនតិច ដែលត្រូវការការស្រាវជ្រាវនិងនវានុវត្តន៍ វាក៏ត្រូវការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ដោយផ្ទាល់ជាចាំបាច់នៅក្នុងពេលបច្ចុប្បន្ននេះ។ ប្រព័ន្ធស្រាវជ្រាវនិងអភិវឌ្ឍន៍ត្រូវការនូវពេលវេលាដើម្បីអភិវឌ្ឍនិងគាំទ្រការអនុវត្តនវានុវត្តន៍របស់ក្រុមហ៊ុនយ៉ាងមានប្រសិទ្ធភាព។ ទោះបីយ៉ាងណាក៏ដោយកម្ពុជានៅមានដែនកំណត់លើសមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍន៍នៅឡើយ ដូច្នេះធ្វើឱ្យទំនាក់ទំនងរវាងសាកលវិទ្យាល័យនិងក្រុមហ៊ុននៅតែទន់ខ្សោយ។ កម្ពុជាជាប់ចំណាត់ថ្នាក់ទី១១៧ នៃ១៤១ប្រទេសក្នុងសូចនាករគុណភាពនៃស្ថាប័នស្រាវជ្រាវក្នុងសន្ទស្សន៍ការប្រកួតប្រជែងសកលក្នុងឆ្នាំ២០១៨ ដែលនៅខ្សោយខ្លាំងជាងប្រទេសថៃ(៤៣) និងប្រទេសវៀតណាម(៥៨)(WEF,2019)។

យោងទៅតាមលោក Dy(2013) ហេតុផលចំនួន៤ ឬ៥ អាចពន្យល់ពីសមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ដែលមានដែនកំណត់។ *ទី១ ប្រទេសកម្ពុជានៅមានការខ្វះខាតក្នុងការផ្តល់ហិរញ្ញវត្ថុដើម្បីអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនិងនវានុវត្តន៍ក្នុងសាកលវិទ្យាល័យនិងវិទ្យាស្ថានស្រាវជ្រាវសាធារណៈ។ ពួកគេនៅតែអាស្រ័យទៅលើដៃគូអភិវឌ្ឍន៍ដូចជាធនាគារពិភពលោក(World Bank) UNDP និងADB ដើម្បីផ្តល់មូលនិធិសម្រាប់គម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍។ ទី២ ការគ្រប់គ្រងការស្រាវជ្រាវនិងនវានុវត្តន៍គឺមិនគ្រប់គ្រាន់ទេ ពីព្រោះរដ្ឋាភិបាលមិនបានផ្តោតការយកចិត្តទុកដាក់ជាលក្ខណៈនយោបាយដើម្បីពង្រីកឱកាសទៅលើការស្រាវជ្រាវនិងនវានុវត្តន៍ទៅក្នុងតំបន់ផ្សេងៗទៀត ជាពិសេសតំបន់ដែលមានភាពភ្លោចខ្លាំងខាងនយោបាយ។ ទី៣ ប្រព័ន្ធលើកទឹកចិត្តនិងផ្តល់រង្វាន់គឺមិនមាន ឬមានតិចតួចសម្រាប់ការលើកទឹកចិត្តការស្រាវជ្រាវរបស់ធនធានមនុស្សដែលមានសមត្ថភាពខ្ពស់នៅក្នុងស្ថាប័នឧត្តមសិក្សា និងស្ថាប័នស្រាវជ្រាវសាធារណៈដើម្បីចូលរួមសកម្មភាពស្រាវជ្រាវ។ ទី៤ ស្ថាប័នឧត្តមសិក្សាគឺកំពុងប្រតិបត្តិការដូចជាសហគ្រាសពាណិជ្ជកម្មដើម្បីផ្តល់នូវសេវាកម្មអប់រំដោយមិនអើពើទៅលើការស្រាវជ្រាវ។ ពួកគេប្រហែលជាកំពុង បណ្តុះបណ្តាលធនធានមនុស្សដែលខ្វះជំនាញស្រាវជ្រាវដែលជាជំនាញដ៏សំខាន់សម្រាប់ការអភិវឌ្ឍជាតិក្នុងពេលអនាគត ឬទីផ្សារពលកម្ម។ ចុងក្រោយកិច្ចសហប្រតិបត្តិការរវាងសាធារណៈនិងឯកជនកម្រកើតឡើងពីព្រោះវប្បធម៌ស្រាវជ្រាវនៅមានកម្រិតនៅក្នុងប្រទេសកម្ពុជា។*

ប្រទេសកម្ពុជាមានសមត្ថភាពគ្រប់គ្រង និងជំនាញនៃកម្លាំងពលកម្មមានកម្រិតក្នុងចំណោមសហគ្រាសខ្នាតតូចនិងមធ្យម។ យោងទៅតាម OECD(2018a) ក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជាមានដែនកំណត់នូវសមត្ថភាពស្រូបទាញចំណេះដឹងថ្មី ពីព្រោះវិស័យសេវាកម្មអភិវឌ្ឍអាជីវកម្មគឺទើបតែលេចឡើងនិងការគាំទ្ររដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពស្រូបទាញចំណេះដឹងថ្មីគឺនៅមានកម្រិតទាបនៅទូទាំងប្រទេស(MIH, 2015)។ ប្រទេសកម្ពុជាទើបតែបានចាប់ផ្តើមជំរុញនិងពង្រឹងសមត្ថភាពសហគ្រាសមីក្រូដែលប្រើប្រាស់នូវគំរូអាជីវកម្មបែបប្រពៃណី(Totten at al., 2019)។ មួយវិញទៀត ទោះបីជាប្រទេសកម្ពុជាបានអភិវឌ្ឍឯកសារគោលនយោបាយដែលផ្តោតទៅលើការអភិវឌ្ឍផលិតភាព និងគំនិតច្នៃប្រឌិត កម្ពុជាអនុវត្តវាមិនទាន់មានប្រសិទ្ធភាពនៅឡើយ(OECD, 2018b; MIH, 2015)។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធរៀនសូត្រជាតិដោយការប្រើប្រាស់នូវទស្សនាទានទំនាក់ទំនងរវាងសាកលវិទ្យាល័យនិងឧស្សាហកម្ម កម្ពុជាត្រូវអភិវឌ្ឍនូវកម្មវិធីហ្វឹកហ្វឺនសមត្ថភាពគ្រប់គ្រងដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តគ្រប់គ្រងរបស់សាកលវិទ្យាល័យនិងក្រុមហ៊ុនក្នុងស្រុក។ នៅពេលសមត្ថភាពគ្រប់គ្រងរបស់ពួកគេប្រសើរឡើង ពួកគេអាចគ្រប់គ្រងធនធានដែលមានស្រាប់យ៉ាងមានប្រសិទ្ធភាព និងមាននិន្នាការទៅរកការទំនាក់ទំនងគ្នាដើម្បីរៀនសូត្រចំណេះដឹងនិងបច្ចេកវិទ្យាថ្មី។ សាកលវិទ្យាល័យអាចយល់ដឹងពីជំនាញនិងបច្ចេកវិទ្យាដែលជាតម្រូវការរបស់វិស័យឯកជន និងអាចអភិវឌ្ឍន៍កម្មវិធីសិក្សានិងបច្ចេកវិទ្យាដើម្បីគាំទ្រវិស័យឯកជន។ មួយវិញទៀត ក្រុមហ៊ុនអាចយល់ដឹងពីឱកាសបច្ចេកវិទ្យា និងអាចគ្រប់គ្រងធនធានរបស់ពួកគេ ដើម្បីទំនាក់ទំនងជាមួយសាកលវិទ្យាល័យ និងរៀនសូត្រនូវបច្ចេកវិទ្យាថ្មីៗពីសាកលវិទ្យាល័យទាំងនោះ។ យោងទៅលើ CDRI(2018a)កម្ពុជាត្រូវជំរុញការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យារួមគ្នារវាងសាកលវិទ្យាល័យនិងឧស្សាហកម្មសម្រាប់ជំរុញឧស្សាហកម្មអាទិភាព។ ក្នុងកិច្ចសហប្រតិបត្តិការបច្ចេកទេសនិងភាពជាដៃគូរវាងសាកលវិទ្យាល័យនិងឧស្សាហកម្មក៏សំខាន់ផងដែរ ដើម្បីធ្វើឱ្យប្រសើរនូវជំនាញរបស់អ្នកសិក្សា STEM ឱ្យមានជំនាញដែលត្រូវនឹងតម្រូវការការងារក្នុងឧស្សាហកម្ម4.0។ រដ្ឋាភិបាលគួរតែប្រើប្រាស់នូវទស្សនាទានទំនាក់ទំនងរវាងសាកលវិទ្យាល័យនិងឧស្សាហកម្ម ដើម្បីធ្វើការអង្កេតពីតម្រូវការការងារក្នុងពេលអនាគត និងតម្រូវការទីផ្សារពលកម្មក្នុងវិស័យថ្មីៗដែលទទួលបានធាតុចូលពីសហគ្រាសអាជីវកម្មតាមរយៈការសហការរបស់ពួកគេជាមួយនឹងស្ថាប័នអប់រំ ហ្វឹកហ្វឺន និងភ្នាក់ងាររដ្ឋាភិបាល។ សហគ្រាសអាជីវកម្មទាំងនោះអាចប្រមូលផ្តុំធនធានរបស់ពួកគេ ដើម្បីអភិវឌ្ឍនូវជំនាញថ្មីដែលត្រូវការក្នុងវិស័យអាទិភាពក្នុងពេលអនាគតដោយការជំរុញកិច្ចសហប្រតិបត្តិការឆ្លងកាត់ឧស្សាហកម្ម និងភាពជាដៃគូសាធារណៈ និងឯកជន។

## ឯកសារយោង


CDRI (2018a). Industry 4.0: Prospects and Challenges for Cambodia' s Manufacturing Sector.

CDRI (2018b). Cambodia Outlook Brief: Science and Technology for Industrialization, Economic Growth, and Development in Cambodia.

Dy, S. S. (2013). Chapter 4: Case Study: Effectiveness of Research and Innovation Management at Policy and Institutional Levels in Cambodia. In Olsson, A., Meek, L. (2013). Effectiveness of Research and Innovation Management at Policy and Institutional Levels: Cambodia, Malaysia, Thailand, and Vietnam. OECD Publishing.

Freeman, C. (2004). Technological Infrastructure and International Competitiveness. Industrial and Corporate Change, Volume 13, Number 3, p. 541-569.

Lundvall, B-A (2010). National Systems of Innovation: Toward a Theory of Innovation and Interactive Learning. London: Pinter Publishers.

Ministry of Industry and Handicraft (2015). Project for Strategic Strengthening of Small and Medium Enterprise Support System. Kingdom of Cambodia, Phnom Penh.

OECD (2018a). OECD Investment Policy Reviews: Cambodia 2018. OECD Publishing, Paris.

OECD (2018b). SME Policy Index: ASEAN 2018. Boosting Competitiveness and Inclusive Growth. OECD Publishing, Paris.

Sam, C., Dahles, H. (2016). Higher Education Development in Cambodia: Implications for the ASEAN Economic Community.

Sam, C., Dahles, H. (2017). Stakeholder Involvement in the Higher Education Sector in Cambodia. Studies in Higher Education, 42:9, p. 1764-1784.

Totten, D., Linna, K., Smiddy, M. (2019). Cambodia: Entrepreneurial Ecosystem Assessment. DGGF, Phnom Penh.

World Economic Forum (2019). The Global Competitiveness Report 2019. World Economic Forum, Geneva.